# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគម្រោងនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ស្តីពីកិច្ចប្រជុំលើកទី៥៩ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ គណៈកម្មការប្រឹក្សាគម្រោង (PAC) នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) របស់អង្គការ ILO បានបើកកិច្ចប្រជុំលើកទី ៥៩។ គណៈកម្មការប្រឹក្សាគម្រោងមានតំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា រួមមានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) និងក្រសួងពាណិជ្ជកម្ម (MoC) តំណាងនិយោជក (តំណាងដោយសមាគមក្នុងវិស័យចំនួនបីនៅកម្ពុជា) និងតំណាងកម្មករនិយោជិត (តំណាងមកពីសហភាព និងសហព័ន្ធសហជីពផ្សេងៗ)។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាភ្ជាប់ពាណិជ្ជកម្មជាមួយលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ (GFT) នៅកម្ពុជា ដើម្បីលើកកម្ពស់ការអនុលោមតាមច្បាប់ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃច្បាប់ការងារជាតិ និងស្តង់ដារការងារស្នូលដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ អភិក្រមរបស់កម្មវិធីរួមមាន ការជំរុញកិច្ចសន្ទនាសង្គមតាមរយៈគណៈកម្មការរួមរវាងតំណាងអ្នកគ្រប់គ្រង និងតំណាងកម្មករ ការផ្តល់សេវាប្រឹក្សាតាមតម្រូវការដល់រោងចក្រ ដែលគាំទ្រពួកគេក្នុងការដោះស្រាយបញ្ហាប្រឈមច្បាប់ស្តីពីការងារ ការពង្រឹងប្រព័ន្ធគ្រប់គ្រងសហគ្រាស និងការប្រើប្រាស់ការរាយការណ៍ជាសាធារណៈដើម្បីជំរុញការកែលម្អលក្ខខណ្ឌការងារ និងបរិយាកាសកន្លែងធ្វើការនៅក្នុងវិស័យទាំងមូល។

1. គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា បច្ចុប្បន្នកំពុងនៅក្នុងឆ្នាំទីបួន នៃការអនុវត្តដំណាក់កាលឆ្នាំ ២០២៣-២០២៧ នៃអនុស្សរណៈនៃការយោគយល់គ្នា (MOU) និងយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ខ្លួនជាមួយដៃគូ។ ក្នុងនាមជាសមាជិក PAC នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា យើងសូមបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើងលើការរួមគ្នាក្នុងការគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ BFC។ យើងប្តេជ្ញាបង្កើនកិច្ចសហការ និងការអនុវត្តសកម្មភាពរួមគ្នាក្នុងរយៈពេលដែលនៅសល់នៃ អនុស្សរណៈបច្ចុប្បន្ន ដែល ជាមូលដ្ឋានរឹងមាំសម្រាប់តាក់តែងអនុស្សរណៈដំណាក់កាលបន្ទាប់របស់កម្មវិធី ដើម្បីធានានិរន្តរភាព និងពង្រីកភាពវិជ្ជមានដែលសម្រេចបានក្នុងការកែលម្អលក្ខខណ្ឌការងារនៅក្នុងវិស័យ GFT នៅកម្ពុជា។
2. សមាជិក PAC បានកត់សម្គាល់ថា ទោះបីជាមានបញ្ហាប្រឈម ជាសកលដែលជះឥទ្ធិពលដល់ប្រតិបត្តិការអាជីវកម្មយ៉ាងណាក៏ដោយ វិស័យកាត់ដេរ ស្បែកជើង

និងផលិតផលធ្វើដំណើរ (GFT) របស់កម្ពុជានៅតែមានភាពធន់។ សមាជិកបានស្វាគមន៍ចំពោះវឌ្ឍនភាពរបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាក្នុងរយៈពេលប្រាំមួយខែកន្លងមកនេះ ក្នុងការពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់សមភាពយេនឌ័រ សុវត្ថិភាពនិងសុខភាពការងារ ប្រាក់ឈ្នួលឌីជីថល និងបរិយាបន្នហិរញ្ញវត្ថុ ខណៈដែលបន្តការច្នៃប្រឌិតវិធីសាស្ត្រនៃការចូលរួមរបស់រោងចក្រ និងការពង្រឹងភាពជាដៃគូ ដើម្បីគាំទ្រដល់និរន្តរភាពរយៈពេលវែងរបស់វិស័យនេះ។

3. សមាជិក PAC បានពិភាក្សាអំពីគំរូសេវាកម្មថ្មី ដែលស្នើឡើងដោយគម្រោងការងារកាន់តែប្រសើរ (Better Work) ដែលបានរៀបចំឡើងដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងរោងចក្រ លើកកម្ពស់កិច្ចសន្ទនាសង្គម និងជំរុញភាពជាម្ចាស់របស់រោងចក្រ ដើម្បីធានាបាននូវការកែលម្អជាបន្តបន្ទាប់ និងប្រកបដោយនិរន្តរភាព។ ដោយផ្អែកលើ ទិន្នន័យរបស់គម្រោង Better Work និងជាការឆ្លើយតបទៅនឹងការកើនឡើងនៃការរំពឹងទុកជាសកលទាក់ទងនឹងការទទួលខុសត្រូវផ្នែកសិទ្ធិមនុស្សនិងបរិស្ថាន (HREDD) សមាជិក PAC បានគាំទ្រដល់ការអនុវត្តសាកល្បងនូវគំរូសេវាកម្មថ្មី ដែលបានស្នើឡើងនេះនៅកម្ពុជា។ សមាជិកបានកត់សម្គាល់ថា ការសាកល្បងនេះនឹងត្រូវអនុវត្តជាមួយរោងចក្រដោយឈរលើគោលការណ៍ស្ម័គ្រចិត្តសម្រាប់រយៈពេល ១២ ខែ ដោយមានការចូលរួមជាបន្តបន្ទាប់ពីសំណាក់រោងចក្រ អ្នកបញ្ជាទិញ (brands) និងសមាជិករបស់ PAC ដើម្បីផ្តល់ព័ត៌មានបន្ថែមអំពីវឌ្ឍនភាព ប្រមូលមតិយោបល់ និងកែសម្រួលគំរូថ្មី នេះតាមការចាំបាច់។
4. សមាជិក PAC បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធនានាក្នុងវិស័យ GFT ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗក្នុងឧស្សាហកម្ម និងគាំទ្រដល់និរន្តរភាព គណនេយ្យភាព និងកេរ្តិ៍ឈ្មោះរបស់វិស័យនេះ។ បន្ទាប់ពីបានពិចារណាលើការរកឃើញនៃសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ ២០២៥ របស់ BFC សមាជិកបានស្វាគមន៍ចំពោះការធានាបានការអនុលោមតាមច្បាប់កម្រិតខ្ពស់ជាបន្តបន្ទាប់នៅក្នុងផ្នែកពលកម្មកុមារ ពលកម្មដោយបង្ខំ និងការរើសអើង។ ក្នុងពេលជាមួយគ្នានេះ PAC បានទទួលស្គាល់ថាផ្នែកសុវត្ថិភាព និងសុខភាព នៅតែជាផ្នែកអាទិភាពដែលទាមទារការយកចិត្តទុកដាក់ជាបន្ត។ ក្នុងន័យនេះ សមាជិក PAC បានលើកទឹកចិត្តយ៉ាងខ្លាំងឱ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈពន្លឿនការបង្កើតច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ព្រមទាំងពង្រឹងការធ្វើអធិការកិច្ចលើសុវត្ថិភាពនិងសុខភាពការងារនៅក្នុងវិស័យ GFT និងវិស័យគាំទ្រផ្សេងទៀត រួមមានទាំងវិស័យសំណង់ផងដែរ។ សមាជិក PAC បានសង្កត់ធ្ងន់លើសារៈសំខាន់នៃវិធានការជាក់ស្តែង និងចំគោលដៅដើម្បីពង្រឹង ផ្នែកសុវត្ថិភាព និងសុខភាពការងារ រួមទាំងតាមរយៈវិធានការបង្ការ ប្រព័ន្ធគ្រប់គ្រង

កាន់តែរឹងមាំ ការលើកកម្ពស់ការចូលរួមរបស់កម្មករ ការផ្លាស់ប្តូរការអនុវត្តល្អ ដំណោះស្រាយដែលមានប្រសិទ្ធភាពខ្ពស់ និងការសហការជាបន្តបន្ទាប់ក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។

5. PAC បានស្វាគមន៍ដំណឹងស្តីអំពី ប្រទេសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំវេទិកា OECD ស្តីពី ការត្រួតពិនិត្យអនុលោមភាពច្បាប់ ក្នុងវិស័យកាត់ដេរ និងស្បែកជើង (OECD Forum on Due Diligence in the Garment and Footwear Sector) ក្នុងអំឡុងសប្តាហ៍នៃថ្ងៃទី៦ ខែមេសា ឆ្នាំ ២០២៧ ដែលជា លើកទីមួយ ដែលវេទិកានេះនឹងប្រារព្ធឡើងនៅក្រៅទីក្រុងប៉ារីស និងជាលើកទីមួយដែលវាត្រូវបានរៀបចំក្នុងប្រទេសអ្នកផលិត។ វេទិកាដៃគូប្រចាំតំបន់អាស៊ីរបស់គម្រោងការងារកាន់តែប្រសើរ (Better Work) ក៏នឹងត្រូវធ្វើឡើងបន្តបន្ទាប់គ្នានៅក្នុងសប្តាហ៍ដដែលនោះផងដែរ។ សមាជិកបានទទួលស្គាល់ថាព្រឹត្តិការណ៍ទាំងនេះគឺជាឱកាសដ៏សំខាន់មួយ ដើម្បីបង្ហាញពីវិស័យ GFT របស់កម្ពុជា និងបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តរបស់ប្រទេស ចំពោះការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ និងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព។ សមាជិក PAC បានប្តេជ្ញាធ្វើការរួមគ្នាដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាឱ្យមានការរៀបចំវេទិកានេះដោយជោគជ័យ និងដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីព្រឹត្តិការណ៍ដ៏សំខាន់នេះសម្រាប់ វិស័យកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា។

ភ្នំពេញ ខែមិថុនា ឆ្នាំ២០២៦